# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ សរណន

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៣

## សារាចរណែនាំ

### ស្តីពី

### ការរៀបចំខួបលើកទី ៥៤ " ទិវាកុមារអន្តរជាតិ ១ មិថុនា "

ក្នុងគោលបំណងពង្រឹងពង្រីកកិច្ចគាំទ្រ និង លើកស្ទួយសិទ្ធិកុមារ ដែលជាអ្នកបន្តវេនសំរាប់អនាគតនៃប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំ ចាត់តាំង ខួបលើកទី ៥៤ ទិវាកុមារអន្តរជាតិ ១ មិថុនា ២០០៣ ខាងមុខនេះ ដូចតទៅ :

១ - គ្រប់ក្រសួង ស្ថាប័ន និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវផ្សព្វផ្សាយអោយសង្គមជាតិទាំងមូលបានដឹងអំពីប្រវត្តិនៃទិវាកុមារអន្តរជាតិ ១ មិថុនា ដែលជាព្រឹត្តការណ៍កើតមាននាអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីសហ៊ីត្លែរ បានបង្កវិនាសកម្ម កាប់សំលាប់ស្ត្រី និង កុមារ នៅលីឌីសែ ប្រទេសឆេក និង អ៊ូរ៉ាឌូ ប្រទេសបារាំង ។ វិនាសកម្មនេះបានបង្កើតនូវកំហឹងលើពិភពលោក ដែលក្រោយមកគេបានកំណត់យកថ្ងៃ ១ មិថុនា ជាទិវាកុមារអន្តរជាតិ។ សម័យប្រជុំនៃអង្គការសហប្រជាជាតិស្តីពីកុមារនៅទីក្រុង New York ឆ្នាំ ២០០១ បានកំណត់ជាសកលបញ្ហាអាទិភាព ៤ របស់កុមារគឺ : មរណៈភាពមាតា អាហារូបត្ថម្ភ អេដស៍/ជម្ងឺអេដស៍ និង កិច្ចការពារកុមារ ។ ដោយឡែក នៅកម្ពុជា វិនាសកម្មដ៏ខ្លោចផ្សារបស់ប្រជាពលរដ្ឋ និង កុមារកម្ពុជា ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុលពត បានធ្វើអោយគ្រួសារណាក៏មានអនុស្សាវរីយ៍ដ៏ជូរចត់ ស្លាប់ប្តី ស្លាប់កូន ព្រាត់ប្រាស់គ្រួសារ ជាក់ស្តែង ប្រជាពលរដ្ឋខ្មែររាប់លាននាក់ ត្រូវស្លាប់ដោយអយុត្តិធម៌ក្នុងរបបនោះ ។ ការងារកុមារ ត្រូវបានយកចិត្តទុកដាក់ពិសេសចាប់តាំងពីក្រោយថ្ងៃ ៧ មករា ១៩៧៩ មក ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់លើកស្ទួយដល់សិទ្ធិទាំង ៤ របស់កុមារ ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ហើយនៅឆ្នាំ ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរគឺ ការចូលរួមរបស់កុមារក្នុងជំលោះប្រដាប់អាវុធ និង ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និង ការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ។ យុទ្ធនាការទូទាំងប្រទេស " **ផ្តល់ការគាំទ្រចំពោះកុមារ** " ដែលបានធ្វើឡើងនៅឆ្នាំ ២០០១ បានកំណត់បញ្ហាជាអាទិភាព ៣ គឺ ;

ហ

-ត្រូវជំរុញការអប់រំចំពោះកុមារ ទាំងអស់

-មិនត្រូវបោះបង់កុមារណាម្នាក់ដាច់ខាត

-ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ។ សេវាសាធារណៈជាច្រើន ត្រូវបានរៀបចំ ដើម្បីជួយដល់កុមាររងាយរងគ្រោះ ដូចជា យកកុមារអនាថា កុមារកំព្រា មកចិញ្ចឹមបីបាច់ថែរក្សា អោយ រៀនអក្សរ រៀនទូវមុខវិជ្ជាជីវៈ ដើម្បីកែប្រែជីវភាពរស់នៅរបស់គេ ។ ផែនការជាតិប្រាំឆ្នាំប្រឆាំងការជួញ ដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ កំពុងត្រូវបានអនុវត្តប្រកបដោយលទ្ធផលផ្លែផ្កាជាជំហាន១ ។ គោល នយោបាយ កម្មវិធីផ្សេង១ ត្រូវបានធ្វើឡើងយ៉ាងសកម្ម ផុលផុស ដោយស្ថាប័នរាជរដ្ឋាភិបាល អង្គការ ជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលដើម្បីបុព្វហេតុការរស់រាន កិច្ចការពារ និង អភិវឌ្ឍន៍របស់កុមារ ។

២ - ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងពត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំ **ព្យុហយាត្រា មិទ្ទិញ** និង កម្មវិធីកំសាន្តផ្សេង១សំរាប់កុមារ នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៣ អោយបានឱឡារិក អធិកអធម ។

៣ - អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវសហការជាមួយមន្ទីរ ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីជួបជុំសំណេះ សំណាល និង មានការចាត់តាំងកំសាន្តសប្បាយរបស់កុមារ នៅក្នុងមូលដ្ឋានរបស់ខ្លួនទៅតាមលទ្ធភាព ជាក់ស្តែង ។

៤ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាសំរាប់ពិធីនេះ ។

៥ - រាជរដ្ឋាភិបាល សូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង ប្រជា ពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រ ដល់កម្មវិធីនេះ អោយបានផុលផុស អធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់ តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- គ្រប់ខេត្ត-ក្រុង " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ